## I. គោលបំណងនៃការស្ទាបស្ទង់មតិ:

ក្នុងគោលបំណង ដើម្បីរួបចំណែកចំពោះការផ្សះផ្សាជាតិដ៏ពិតប្រាកដ វិទ្យាស្ថានបានធ្វើការស្ទង់បតិមួយទៅលើបទពិសោធន៍របស់ប្រជាពលរដ្ឋខ្មែរក្នុងរបបខ្មែរក្រហម និងក្តីរំពឹងរបស់ពួកគាត់ទៅលើសាលាជំរះក្តីកាត់ទោសខ្មែរក្រហម ដែលនឹងរៀបចំឡើងនៅពេលខាងមុខនេះ ដោយមាន**គោលបំណងពីរយ៉ាង:**

១. ដើម្បីធ្វើឱ្យមន្ត្រីកម្មវិធីវ័យក្មេងប្រាំមួយនាក់របស់វិទ្យាស្ថាន ឱ្យបានដឹងច្បាស់អំពីបទពិសោធន៍ អារម្មណ៍ និងតំរូវការរបស់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។
ដូចគ្នានឹងប្រជាពលរដ្ឋជាង៥០%ទៀតដែរ យុវជនទាំងប្រាំមួយនាក់នេះកើតក្រោយឆ្នាំ ១៩៧៩ ហើយដឹងតិចតួចបំផុតអំពីប្រវត្តិសាស្ត្រនាពេលថ្មីៗនៃប្រទេសរបស់ពួកគាត់ ។ តាមរយៈការជួបសម្ភាសផ្ទាល់ជាមួយសមាជិកនៃជំនាន់មុន បានផ្តល់ឱកាសឱ្យពួកគេស្វែងយល់កាន់តែច្បាស់អំពីអ្វីដែលបានកើតឡើងក្នុងកំឡុងឆ្នាំ ១៩៧៥-១៩៧៩ ហើយអាចធ្វើឱ្យពួកគេកសាងទំនាក់ទំនងជាការបោះជំហានដំបូងឆ្ពោះទៅរកការផ្សះផ្សាគ្នា ។ ក្នុងចំណោមមន្ត្រីកម្មវិធីទាំង៦រូបនេះ មាន ៥រូប ជានិស្សិតបញ្ចប់បរិញ្ញាប័ត្រនីតិសាស្ត្រ និងមួយរូបជានិស្សិតបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ហើយដែលត្រូវបានបណ្តុះបណ្តាល ដើម្បីឱ្យក្លាយជាអ្នកឃ្លាំមើលការកាត់ទោសខ្មែរក្រហម ដែលនឹងប្រព្រឹត្តទៅ នាពេលខាងមុខនេះ ។

២. ធ្វើឱ្យយើងបានដឹងច្បាស់អំពីក្តីសង្ឃឹម និងក្តីរំពឹងទុករបស់អ្នករួចផុតពីសេចក្តីស្លាប់ទៅលើការជំនុំជំរះពួកខ្មែរក្រហម នៅពេលខាងមុខ ដើម្បីរៀបចំគំរោងចុះផ្សព្វផ្សាយមួយអំពីសាលាជំរះក្តីនេះ សំដៅបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការជំនុំជំរះ និងការពង្រឹងនីតិរដ្ឋ ។

ការស្ទង់មតិនេះមិនបានធ្វើឡើងដោយអ្នកជំនាញក្នុងការធ្វើសម្ភាសទេ ហើយក៏មិនបានប្រើប្រាស់វិធីសាស្ត្រ ជាលក្ខណៈវិទ្យាសាស្ត្រដែលមានវិជ្ជាជីវៈឯកទេសដែរ ។ អាស្រ័យហេតុនេះ ការស្ទាបស្ទង់មតិនេះ និងលទ្ធផលរបស់វា **មិនគួរចាត់ទុកជា តំណាងឱ្យប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសទេ** ប៉ុន្តែគួរត្រូវបានចាត់ទុកត្រឹមតែជា មតិរបស់អ្នកផ្តល់ការសម្ភាសន៍តែប៉ុណ្ណោះ ។

## II. ការចុះធ្វើការស្ទាបស្ទង់មតិ

**ការសម្ភាសន៍ចំនួន ៥៣៦ បានធ្វើឡើងនៅក្នុង រាជធានីភ្នំពេញ និងខេត្តចំនួន ១០ នៅចន្លោះពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០០៤** ។ ខេត្តទាំងនេះរួមមាន:

- កំពង់ចាម
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កណ្តាល
- ក្រចេះ
- ព្រៃវែង
- ស្ទឹងត្រែង
- ស្វាយរៀង និង
- តាកែវ




នៅក្នុងការសម្ភាសន៍ដោយផ្ទាល់ យើងបានប្រើ **សំណួរចំនួន ២២** ដើម្បីសម្ភាសប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ **ដែលមានអាយុចាប់ពី ៣០ឆ្នាំ ឡើងទៅ** ។ ប្រជាពលរដ្ឋទាំងនេះ ត្រូវបានជ្រើសរើសដោយចៃដន្យ និងភាពចៃដន្យ ដែលនឹងឆ្លុះបញ្ចាំងនូវតំណាងដ៏សមល្មមនៃសង្គមកម្ពុជា ។ អ្នកទាំងនោះគឺជា អនក្ខរជន និងបញ្ញវន្តមកពីគ្រប់វណ្ណៈសង្គម ។ យើងបានសួរអំពី បទពិសោធន៍នៅក្នុងសម័យខ្មែរក្រហម និងក្តីរំពឹងទុករបស់ពួកគាត់ ចំពោះសាលាជំរះក្តីកាត់ទោសខ្មែរក្រហមនៅពេលខាងមុខនេះ[១] ។

៤៥%នៃប្រជាពលរដ្ឋដែលត្រូវបានសម្ភាសគឺជា ស្ត្រី និង ៥៥%គឺជា បុរស ។

អ្នកដែលត្រូវបានសម្ភាសមានអាយុចាប់ពី ៣០ ដល់ ៨៣ឆ្នាំ ហើយមានអាយុជាមធ្យមគឺ ៤៩ឆ្នាំ ។

៩៨.៩%នៃប្រជាពលរដ្ឋដែលត្រូវបានសម្ភាសន៍គឺជា ពុទ្ធសាសនិកជន ។

អ្នកផ្តល់ការសម្ភាសន៍មានមុខរបរជា កសិករ ៣៣,៣% មន្ត្រីរាជការ ១៣,៨% គ្រូបង្រៀន ១២,២% និងមេផ្ទះ ១២,២% ។

---

[១] រហូតមកដល់ពេលនេះមានការស្ទាបស្ទង់មតិតែបីប៉ុណ្ណោះត្រូវបានធ្វើ:

- Laura McGrew នៅឆ្នាំ ១៩៩៩/២០០០ មើល www.advocacynet.org/news_view/news_37.html
- "មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម" (CSD) នៅឆ្នាំ ២០០០ មើល www.online.com.kh/users/csd/
- Suzannah Linton "មជ្ឈមណ្ឌលឯកសារកម្ពុជា" (DC-Cam) ឆ្នាំ ២០០២, សូមមើល www.dccam.org/Publication%20and%20research/reconciliation_in_cambodia.htm

នៅឆ្នាំ១៩៩៧ ការស្ទង់មតិមួយទៀតត្រូវបានធ្វើឡើង Jaya Ranja និង Christine Baton សំរាប់ DC-Cam ប៉ុន្តែលទ្ធផលនៃការស្ទង់មតិនេះមិនត្រូវបានបោះពុម្ពផ្សាយទេ ។

ពីរភាគបីនៃអ្នកផ្តល់ការសម្ភាសន៍ រស់នៅក្រៅរាជធានីភ្នំពេញ ។ យើងមិនបានទៅដល់តំបន់ទាំងឡាយនៃប្រទេសកម្ពុជា ដែលគេហៅថា "អតីតតំបន់ខ្មែរក្រហម" ដូចជា ប៉ៃលិន ឬអន្លង់វែងទេ ប៉ុន្តែយើងសន្និដ្ឋានថា ក្នុងចំណោមអ្នកផ្តល់ការសម្ភាសន៍ទាំងអស់មួយចំនួនជាប់ទាក់ទងជាមួយខ្មែរក្រហម ។

## ១. ក្រុមការងារស្ទួលដែលទទួលខុសត្រូវ និងអ្នកធ្វើសម្ភាសន៍ផ្សេងទៀត

១.១."ក្រុមការងារស្ទួល" របស់យើងមានសមាជិក ប្រាំពីរនាក់ ជនជាតិខ្មែរប្រាំមួយនាក់ និងបេធារីអាល្លឺម៉ង់ម្នាក់ ក្នុងនោះមានសមាជិកស្រី ប្រាំនាក់ និងប្រុស ពីរនាក់ ។ អ្នកសម្ភាសន៍ខ្មែរទាំងប្រាំមួយនាក់ មានជំនាញក្នុងការធ្វើសម្ភាសន៍ ប៉ុន្តែមិនមែនជា អ្នកធ្វើការសម្ភាសន៍អាជីពទេ ។



មុនពេលធ្វើការសម្ភាសន៍ ក្រុមការងារស្ទួលត្រូវបានណែនាំឱ្យស្គាល់អំពីមាតុភូតនៃ "ជំងឺបាក់ស្បាត" (Post Traumatic Stress Disorder-PTSD) ដោយចិត្តវិទូកាណាដាម្នាក់ និងត្រូវបានបណ្តុះបណ្តាល អំពីវិធីដោះស្រាយនឹងប្រតិកម្មរបស់អ្នកផ្តល់ការសម្ភាសន៍ដែលមានអារម្មណ៍មិននឹងនរ ឬមិនអាចគ្រប់គ្រងអារម្មណ៍បាន ដោយសារមានអារម្មណ៍ហាក់ដូចជាកំពុងស្ថិតនៅក្នុងភាពអតីតកាល ។

ទោះបីជាសមាជិកក្រុមការងារស្ទួលខ្មែរទាំងអស់មានអាយុក្រោម ២៥ឆ្នាំ ក៏ដោយ ក៏ពុំមានសមាជិកណាម្នាក់ជួបការលំបាកក្នុងការនិយាយ ឬប្រាស្រ័យទាក់ទងជាមួយអ្នកផ្តល់សម្ភាសន៍ ដែលមិនមែនជាសាច់ញាតិគេដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឱ្យពួកគេងាយស្រួលបំពេញភារកិច្ចដ៏លំបាកនោះ ជំហានដំបូងនៃការសម្ភាសន៍ ត្រូវបានធ្វើឡើងជាមួយ**សមាជិកគ្រួសារ** ជំហានទីពីរធ្វើជាមួយ**មនុស្សដែលធ្លាប់ស្គាល់គ្នា** ដូចជា អ្នកជិតខាង ឬអតីតគ្រូបង្រៀន និងជំហានទីបីជាមួយ**អ្នកដែលមិនធ្លាប់ស្គាល់** ។ ការធ្វើរបៀបនេះ គឺក្នុងគោលបំណងកសាងទំនុកចិត្តលើខ្លួនឯងរបស់ក្រុមការងារស្ទួល ដើម្បីប្រឈមមុខជាមួយនឹងមនុស្សដែលយើងមិនធ្លាប់ស្គាល់មួយជំហានម្តងៗ ។

**អ្នកផ្តល់ការសម្ភាសន៍របស់ក្រុមការងារស្ទួល**



**ក្រុមការងារស្ទួលបានធ្វើការសម្ភាសន៍ជាមួយប្រជាពលរដ្ឋចំនួន ១៣០នាក់** នៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម កំពង់ស្ពឺ កណ្ដាល និងស្វាយរៀង ។ ការសម្ភាសន៍នេះ[២] ទំនងជាមានភាពត្រឹមត្រូវច្រើនបំផុត ពីព្រោះអ្នកផ្ដល់-ការសម្ភាសន៍ត្រូវបានសាកសួរសំនួរមួយម្ដងៗ ។ សំណួរពិបាកៗត្រូវបានពន្យល់ដល់ពួកគាត់ ដោយយកចិត្តទុកដាក់នៅពេលដែលចាំបាច់ ។

ការសម្ភាសន៍ ចំណាយរយៈពេលជាមធ្យមប្រហែលជា មួយម៉ោងកន្លះ ។

១.២. ក្រៅពីក្រុមការងារស្ទួល **អ្នកធ្វើសម្ភាសន៍ដទៃទៀត**ក៏បានចូលរួមក្នុងការស្ទាបស្ទង់មតិនេះដែរ ។ ក្នុងចំណោមអ្នកទាំងនោះ រួមមានដូចជា :

- បុគ្គលិកវិទ្យាស្ថាន នៅទីស្នាក់កណ្ដាល រាជធានីភ្នំពេញ
- ប្រធាន "មជ្ឈមណ្ឌលព័ត៌មានសហគមន៍" (CIC) របស់វិទ្យាស្ថាន នៅខេត្តកំពង់ចាម ក្រចេះ ស្ទឹងត្រែង និង ស្វាយរៀង
- "ដៃគូ" របស់វិទ្យាស្ថាន នៃកម្មវិធីលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ។ ពួកគាត់ជា នាយក នាយករងសាលា ឬប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលប្រជាពលរដ្ឋនៅក្នុងសហគមន៍គោរពរាប់អានច្រើន ។
- "ទីប្រឹក្សាពលរដ្ឋ" នៃកម្មវិធីសេវាកម្មទីប្រឹក្សាពលរដ្ឋ (អំប៊ុតសមិន) របស់វិទ្យាស្ថាន ។ ពួកគាត់ជាប្រជាពលរដ្ឋមូលដ្ឋានដែលមានគេគោរពរាប់អានច្រើន ដែលចេះអាន ចេះសរសេរ និងផ្ដល់ជាមធ្យោបាយទំនាក់ទំនងរវាងអ្នកមិនចេះអក្សរ និងអាជ្ញាធរមូលដ្ឋាន ។ ពួកគាត់បានទទួលការបណ្ដុះបណ្ដាល អំពីសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ដោយវិទ្យាស្ថាន ដើម្បីផ្ដល់ការណែនាំដល់ប្រជាពលរដ្ឋអំពីប្រធានបទទាំងនេះ ។
- អតីតសិក្ខាកាមនៃសិក្ខាសាលារបស់វិទ្យាស្ថាន ស្ដីពី "ការពិចារណាពិស្ដារផ្នែកគតិយុត្តិ" និង
- មិត្តភក្ដិរបស់ក្រុមការងារស្ទួល

អ្នកគាំទ្រដែលមានសន្ដានចិត្តទាំងនេះ បានសម្ភាសប្រជាពលរដ្ឋសរុបចំនួន **៨០៦នាក់** ។ យើងមិនអាចអះអាងបានទេថា តើក្នុងកំឡុងពេលធ្វើការសម្ភាសន៍នីមួយៗ អ្នកផ្ដល់ការសម្ភាសន៍ត្រូវបានសួរសំណួរដោយផ្ទាល់ ឬថាតើនៅក្នុងករណីខ្លះ អ្នកធ្វើសម្ភាសន៍ចែកកំរងសំណួរឱ្យពួកគេបំពេញខ្លួនឯង ឬក៏យ៉ាងណាទេ ។ លើសពីនេះទៀត វាទំនងដូចជាថា នៅក្នុងករណីមួយចំនួន អ្នកភូមិជួបជុំជាមួយដៃគូ ទីប្រឹក្សាប្រជាពលរដ្ឋ ឬថែមទាំងជាមួយប្រធានភូមិ ឬមន្ត្រីជាន់ខ្ពស់ដទៃទៀត ហើយបានឆ្លើយនូវសំណួរទាំងនោះទាំងអស់គ្នា ជាពិសេស ក្នុងករណីដែលអ្នកផ្ដល់ការសម្ភាសន៍នោះ មិនចេះអាន ឬសរសេរអក្សរ ។

[២] សូមមើល ឧបសម្ព័ន្ធ ស្ដីពី លទ្ធផលនៃការស្ទាបស្ទង់មតិរបស់ក្រុមការងារស្ទួលជាមួយនឹងប្រជាពលរដ្ឋចំនួន ១៣០នាក់ នៅទំព័រទី ២៤ - ៣២

## ២. ការរៀបរៀងគំរូសំណួរ និងការធ្វើសម្ភាសៈ

**២.១.** ដោយដឹងជាមុនអំពីបញ្ហាដែលកើតមានពីការធ្វើសម្ភាសន៍ដោយផ្ទាល់ ដែលថា អ្នកផ្តល់ការសម្ភាសន៍បញ្ចេញនូវមតិយោបល់ "ដែលធ្វើឱ្យអ្នកធ្វើការសម្ភាសន៍ពេញចិត្ត" ជាជាងមតិ "ពិត" នោះ ។ ក្រុមការងារស្ទូល បានជ្រើសរើសយកទំរង់នៃការសម្ភាសន៍ជាលក្ខណៈបុគ្គល ដើម្បីផ្តល់នូវភាពអាចបត់បែនកាន់តែទូលំទូលាយ ចំពោះការបំភ្លឺលើការយល់ច្រឡំ ការបំពេញតំរូវការផ្លូវអារម្មណ៍របស់អ្នកផ្តល់ការសម្ភាសន៍ដែលមានភាពតានតឹងក្នុងចិត្ត និងរាប់បញ្ចូលទាំង អ្នកផ្តល់ការសម្ភាសន៍ដែលមិនចេះអាន ឬសរសេរអក្សរ ។

ក្រុមការងារស្ទូល បាន**ជ្រើសរើសដោយអត្តនោម័តនូវសំណួរជ្រើសរើសចំនួន ២០ និងសំណួរចំហរចំនួន ២** ដែលពួកគេយល់ថាមានអត្ថប្រយោជន៍ ដើម្បីសួរអ្នកផ្តល់ការសម្ភាសន៍ ។ សំណួរទី ៦ (តើអ្វីដែលអ្នកពេញចិត្តជាងគេនៅក្នុងរបបនោះ?) និងសំណួរទី ៧ (តើកត្តាអ្វីខ្លះដែលជួយជំរុញឱ្យអ្នកតស៊ូដើម្បីរស់តទៅទៀតនៅក្នុងរបបខ្មែរ-ក្រហម?) ត្រូវបានព្រាង ដើម្បីទទួលបាននូវទស្សនៈអំពីទិដ្ឋភាពវិជ្ជមាននៃជីវិតរបស់ពួកគេនៅក្រោមរបបខ្មែរក្រហម ។ យើងមានជំនឿថា ទោះបីជានៅក្នុងពេលដ៏លំបាកបែបនោះក៏ដោយ ប្រាកដជាមានហេតុផលមួយចំនួន ដែលបានជំរុញមនុស្សឱ្យរួចផុតពីស្លាប់ ឬមានសង្ឃឹមសំរាប់ពេលដ៏ល្អប្រសើរ ពីព្រោះសូម្បីតែនៅឋាននរកក៏មិនខ្មៅងងឹតទាំងស្រុងដែរ តែងតែមានពន្លឺខ្លះៗជានិច្ច ។ លើសពីនេះទៀត យើងគិតថា ដំណើរការផ្សះផ្សាដ៏ពិតប្រាកដមួយមានសារៈសំខាន់បំផុតក្នុងការពិនិត្យលើរាល់ទិដ្ឋភាពទាំងអស់នៃជីវិតនៅក្នុងសម័យនោះ មិនមែនមានត្រឹមតែទិដ្ឋភាពដែលអាក្រក់ប៉ុណ្ណោះទេ ។

**២.២.** មុនពេលការសម្ភាសន៍នីមួយៗ អ្នកធ្វើការសម្ភាសន៍ត្រូវដឹងច្បាស់ថា អ្នកផ្តល់ការសម្ភាសន៍មានអាយុចាប់ពី ៣០ឆ្នាំ ឡើងទៅ ។ ដូច្នេះ អ្នកផ្តល់ការសម្ភាសន៍ទាំងអស់ សុទ្ធតែធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម មិនថានៅវ័យកុមារ មនុស្សពេញវ័យ ឬក៏មនុស្សចាស់ឡើយ ។

អ្នកធ្វើការសម្ភាសន៍ ក៏បានព្យាយាមផងដែរ ដើម្បីថ្លឹងថ្លែងដោយប្រុងប្រយ័ត្នលើតុល្យភាពយេនឌ័រ ក្នុងការជ្រើសរើសអ្នកផ្តល់ការសម្ភាសន៍ ។

មុនពេលសួរសំណួរ អ្នកធ្វើការសម្ភាសន៍បានព្យាយាមបង្កើតនូវ**បរិយាសទុកចិត្តគ្នាមួយ** ដោយធ្វើការណែនាំខ្លួនគេជាដំបូង តាមរយៈការឱ្យនាមប័ណ្ណជាបុគ្គលិកវិទ្យាស្ថាន ។ ទីពីរ ពួកគេបានប្រាប់អ្នកផ្តល់ការសម្ភាសន៍ថា ការសម្ភាសន៍នេះត្រូវធ្វើឡើងដោយការស្ម័គ្រចិត្ត ។ អ្នកធ្វើការសម្ភាសន៍ បានសុំពេលវេលារបស់ពួកគាត់ ប្រហែលជាពីរម៉ោង សំរាប់ធ្វើការសម្ភាសន៍ ។ បន្ទាប់មក អ្នកធ្វើការសម្ភាសន៍បានពន្យល់ពួកគាត់អំពីគោលបំណងទាំងពីរនៃការស្ទាបស្ទង់មតិនេះ ហើយធានាថា អត្តសញ្ញាណរបស់ពួកគាត់នឹងត្រូវបានរក្សាជាការសំងាត់ ។ យើងមិនបានសួរឈ្មោះរបស់ពួកគាត់ទេ ។

នៅក្នុងករណីខ្លះ វាមានប្រយោជន៍ដែលត្រូវពន្យល់បន្ថែមអំពី **ទស្សនៈវិស័យរបស់វិទ្យាស្ថានទៅលើគំរោងនេះ** ឱ្យបានពិស្តារថែមទៀតៈ

- អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ នឹងមិនត្រូវកើតឡើងនៅប្រទេសកម្ពុជាម្តងទៀតឡើយ។
- ហេតុដូច្នេះហើយ យើងខិតខំប្រឹងប្រែងដើម្បីកម្ពុជាមួយ ដែលមានការគោរពនីតិរដ្ឋ មានតុលាការមួយឯករាជ្យ និងមិនលំអៀង ជាអ្នកតាមដានការអនុវត្តន៍នូវគោលការណ៍កាត់ក្តី ដោយយុត្តិធម៌សំរាប់ប្រជាពលរដ្ឋខ្មែរ។
- យើងមានបំណងរួមចំណែក ក្នុងបរិយាកាសជឿជាក់មួយ រវាងប្រជាពលរដ្ឋខ្មែរ ។ ដូច្នេះ ភាពតក់ស្លុតដែលបានបន្សល់ទុកពីសម័យ ប៉ុល ពត អាចលុបបំបាត់បាន និងបង្កើនការយោគយល់គ្នាទៅវិញទៅមករវាងឧក្រិដ្ឋជននឹងជនរងគ្រោះ ។
- សំរាប់ប្រទេសកម្ពុជារបស់យើងនាពេលអនាគត ប្រជាពលរដ្ឋទាំងអស់ នឹងត្រូវទទួលបាននូវសុខសន្តិភាពយ៉ាងពិតប្រាកដ បន្ទាប់ពីដំណើរការផ្សះផ្សាជាតិ ហើយនឹងទទួលបាននូវសិទ្ធិរបស់ពួកគេ ដើម្បីសង្គមប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍ប្រទេសឱ្យកាន់តែប្រសើរឡើង។

ក្នុងកំឡុងពេលសម្ភាសន៍ យើងមិនជំរុញឱ្យមានវត្តមានបុគ្គលទីបីឡើយ ។ ប្រតិកម្មនៃការវាយតំលៃទៅលើអ្វីដែលអ្នកផ្តល់បទសម្ភាសន៍បាននិយាយត្រូវបានជៀសវាង ។ ផ្ទុយទៅវិញ អ្នកធ្វើការសម្ភាសន៍បានបង្ហាញនូវការយល់ចិត្ត និងការយោគយល់ ។ រាល់ពេលធ្វើសម្ភាសន៍ទាំងអស់ លេខទូរស័ព្ទរបស់វេជ្ជបណ្ឌិតពីរនាក់ ម្នាក់បំរើការនៅ "អង្គការចិត្តសាស្ត្រសង្គមអន្តរវប្បធម៌" (TPO) និងម្នាក់ទៀតបំរើការនៅ "មជ្ឈមណ្ឌលជាតិជនពិការ" (NCDP) ត្រូវបានរក្សាទុកជិតដៃជានិច្ច ក្នុងករណីមានសញ្ញាធ្ងន់ធ្ងរនៃជំងឺបាក់ស្បាត (PTSD) ។ វេជ្ជបណ្ឌិតទាំងពីររូបនេះត្រូវបានជូនដំណឹងជាមុនអំពីការស្ទង់មតិនេះ ហើយបានយល់ព្រមជួយក្នុងករណីភាពអាសន្ន ។ ជាសំណាងល្អពុំមានស្ថានភាពអាក្រក់ណាមួយបានកើតឡើង ក្នុងកំឡុងពេលធ្វើការសម្ភាសន៍ឡើយ ។

## ៣. បទពិសោធន៍របស់ក្រុមការងារស្ទង់ :

**កំរងសំណួរដែលបានចែកចាយសរុបចំនួន ៦៣៦ មានជាង ៨៤% (=៥៣៦) ត្រូវបានបំពេញ ហើយផ្ញើមកឱ្យវិទ្យាស្ថានវិញ** ដែលបង្ហាញនូវជោគជ័យមួយសំរាប់គំរោងនេះ ។

ការចូលរួមដ៏ទូលំទូលាយរបស់ផ្តល់ការសម្ភាសន៍ និងឥរិយាបទរបស់ពួកគាត់ក្នុងការពន្យល់ដោយ ពិស្តារនូវអ្វីដែលបានកើតឡើងចំពោះពួកគាត់ បានបង្ហាញថា ភាគច្រើននៃអ្នកឆ្លើយសំណួរមិនចង់ ឬមិនអាចបំភ្លេចរឿងដែលកន្លងផុតទៅហើយបានឡើយ ។ ពួកគាត់ភាគច្រើនមិនចង់ឱ្យគេរំខាននៅពេលដែលកំពុងឆ្លើយសំណួរទេ ។ ជួនកាល អ្នកធ្វើការសម្ភាសន៍មានការពិបាកបន្តទៅសំណួរបន្ទាប់ទៀត ពីព្រោះពួកគាត់ចង់បន្ថែមហើយបន្ថែមទៀតទៅលើសំណួរនីមួយៗ ហើយត្រឡប់ទៅសំណួរមុនៗវិញជាញឹកញាប់ ។ សំរាប់ប្រជាពលរដ្ឋខ្លះ ការសម្ភាសន៍នេះអាចត្រូវប្រើពេលអស់ជាច្រើនម៉ោង ។ ដូច្នេះ វាសំខាន់ណាស់ដែលយើងបានកំណត់ពេលវេលា នៃការសម្ភាសន៍ពីរម៉ោង ឬលើសពីនេះសំរាប់ការសម្ភាសន៍នីមួយៗ ។

អ្នកផ្តល់ការសម្ភាសន៍កប្របង្ហាញនូវភាពនឿយហត់ ឬការមិនអត់ធន់ ទោះបីជាពួកគេត្រូវបានសួរសំណួរដល់ទៅ ២២សំណួរ ហើយក្នុងនោះសំណួរមួយចំនួនមានការពិបាកក្នុងការឆ្លើយ ។

អ្នកផ្តល់ការសម្ភាសន៍ភាគច្រើនហាក់ដូចជានិយាយដោយស្មោះក្នុងការឆ្លើយនូវសំណួរទាំងឡាយ ហើយមិនបានកាលំបាកក្នុងការបង្ហាញពីអារម្មណ៍ និងតំរូវការពិតប្រាកដរបស់ខ្លួនឡើយ ។ មានអ្នកផ្តល់ការសម្ភាសន៍តែមួយចំនួនតូច

ប៉ុណ្ណោះ ដែលមានបន្ទិលសង្ស័យអំពីប្រធានបទ ហើយបានសួរថា តើអ្នកសម្ភាសន៍មកពីគណបក្សនយោបាយមែនឬទេ។ អ្នកផ្តល់ការសម្ភាសន៍តិចតួចប៉ុណ្ណោះ ដែលមានអារម្មណ៍មិនស្រួលនៅពេលចាប់ផ្តើមនិយាយដំបូង ប៉ុន្តែពួកគាត់បានទទួលនូវទំនុកចិត្តយ៉ាងឆាប់រហ័សក្នុងកំឡុងពេលសម្ភាសន៍ ដោយពួកគាត់មានអារម្មណ៍ថា អ្នកធ្វើការសម្ភាសន៍គោរពពួកគាត់ ។

ក្រុមការងារស្ទួលរីករាយ និងពេញចិត្តចំពោះអ្នកផ្តល់ការសម្ភាសន៍ ដែលបានចែករំលែកនូវបទពិសោធន៍ដ៏ជូរចត់របស់ពួកគាត់ ។ ការនេះ ធ្វើឱ្យយើងបានចប្វល់កាន់តែច្រើន ហើយចង់ដឹងថែមទៀត ។ យើងក៏បានពិចារណាច្រើនផងដែរអំពីបទពិសោធន៍នៃសមាជិកគ្រួសាររបស់យើងដែលយើងមិនធ្លាប់បានដឹងពីមុនមក ។

ប្យ៉ាងវិញទៀត យើងសោកស្តាយ និងមានអារម្មណ៍តក់ស្លុតចំពោះរឿងរ៉ាវលំបាកទាំងឡាយដែលយើងបានស្តាប់ឮដោយផ្ទាល់ពីអ្នកនៅរស់ទាំងអស់ ជាលើកដំបូងក្នុងជីវិតរបស់យើង ។ ជួនកាល អ្នកផ្តល់ការសម្ភាសន៍ យំ និងត្រូវការការយកចិត្តទុកដាក់ពីអ្នកធ្វើការសម្ភាសន៍ ។ នេះគឺជា បញ្ហាប្រឈមផ្ទាល់ខ្លួនសំរាប់អ្នកធ្វើការសម្ភាសន៍ទាំងអស់ ។ ប៉ុន្តែអារម្មណ៍ដែលនៅសេសសល់គឺជាទំនុកចិត្តលើខ្លួនឯងរបស់ក្រុមការងារស្ទួលក្នុងការនិយាយដោយស្មោះត្រង់ជាមួយប្រជាពលរដ្ឋ អំពីរបបខ្មែរក្រហម និងមានអារម្មណ៍ជ្រះថ្លាក្នុងការសួរនូវសំណួរបែបស្និទ្ធស្នាល ។

យើងបានរៀនសូត្រ ដើម្បីទំនាក់ទំនង និងសម្របខ្លួនទៅតាមបុគ្គលិកលក្ខណៈបុគ្គលខុសៗគ្នា ។

## III. លទ្ធផលចំបងបំផុតនៃការស្ទាបស្ទង់មតិ

តាមទស្សនៈរបស់វិទ្យាស្ថាន **លទ្ធផលដ៏សំខាន់បំផុត**ដែលទទួលបានពីការស្រាវជ្រាវនេះមានដូចខាងក្រោម៖




៧៦,៩% នៃអ្នកផ្តល់ការសម្ភាសន៍នៅតែគិតអំពីអតីតកាល ពីព្រោះពួកគាត់នៅតែខឹងនឹងអ្វីដែលបានកើតឡើងដល់ពួកគាត់ ។ ៨៨,៦%ឆ្ងល់ថា តើហេតុអ្វីបានជាពួកគាត់ត្រូវឆ្លងកាត់នូវបទពិសោធន៍ដ៏អាក្រក់នោះ ហើយ៩២,៧% នៃអ្នកឆ្លើយសំណួរនៅតែមានអារម្មណ៍ភ័យខ្លាច[៣] ។

[៣] គួរកត់សំគាល់ថា សំណួរនីមួយៗអាចមានចំលើយច្រើនឱ្យជ្រើសរើស ដូច្នេះផលបូកនៃភាគរយមិនស្មើនឹង ១០០%ជានិច្ចនោះទេ ។